# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងយុត្តិធម៌
លេខ ៣២៥ .រប-៩៣

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ជម្រាបមក**

**លោកប្រធានតុលាការគ្រប់ ខេត្ត ក្រុង**

*សូមជ្រាប។*

**កម្មវត្ថុ:** ការរៀបចំសំណុំរឿងបញ្ជូនទៅសាលាឧទ្ធរណ៍

**យោង:** ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ០៦ ចុះថ្ងៃទី ០៨-០២-៩៣ ។

តាមកម្មវត្ថុ និងយោងខាងលើ ក្រសួងយុត្តិធម៌សូមជម្រាបលោកប្រធានតុលាការខេត្ត ក្រុងទាំងអស់ថា គ្រប់រឿងក្តីទាំងអស់ដែលតុលាការជំនុំជម្រះរួចហើយតែត្រូវភាគីណាមួយមិនសុខចិត្ត ហើយប្តឹងឧទ្ធរណ៍តាមអំណាច្បាប់បើកផ្លូវឲ្យប្តឹងនោះ តុលាការខេត្ត ក្រុងទាំងអស់ត្រូវរៀបចំសំណុំរឿងទាំងនោះទៅតាមនីតិវិធីនៃបែបបទប្តឹងឧទ្ធរណ៍ត្រៀមបញ្ជូនទៅសាលាឧទ្ធរណ៍ ដើម្បីធានានូវប្រយោជន៍ដល់គូក្តីដែលទាក់ទងក្នុងរឿងនិងធានាភាពត្រឹមត្រូវតាមផ្លូវច្បាប់នៅពេលណាសាលាឧទ្ធរណ៍បើកដំណើរការជាផ្លូវការ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០៩ ខែកក្កដា ឆ្នាំ១៩៩៣

**រដ្ឋមន្ត្រី**

**ចែម ស្នួន**